**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចប្រជុំ**

**រវាង**

**តំណាងរោងចក្រ ជេ អេ ដាប់ប៊ែលយូ ៦.ក**

**និង**

**សហជីពមូលដ្ឋាន និងប្រតិភូបុគ្គលិក**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ វេលាម៉ោង១៣ និង០០នាទី នៅក្នុងរោងចក្រ **ជេ អេ ដាប់ប៊ែលយូ ៦.ក** មានទីតាំងផ្លូវលំ ភូមិជំរៅ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន សហជីពមូលដ្ឋាន និងប្រតិភូបុគ្គលិក ស្តីអំពីការព្យួរកិច្ចសន្យាការងារ ។

នៅក្នុងអង្គប្រជុំនេះ តំណាងក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រថា ដោយសារជួបវិបត្តិសេដ្ឋកិច្ចជាសកល ក្រុមហ៊ុនយើងខ្ញុំខ្វះសម្ភារវត្ថុធាតុដើមសម្រាប់ផលិត (ពុំមានការបញ្ជាទិញ) ដែលមិនអាចអោយចង្វាក់ផលិតកម្មរបស់រោងចក្រដំណើរការបាន ហេតុដូចនេះ ក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងារកម្មករ និយោជិតចំនួន**៨២១នាក់** ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន **៨២១នាក់** (ស្រី ៧៣៥នាក់ ) រយៈពេលចំនួន **១៤ថ្ងៃ** គឺចាប់ពី **ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០២៣** ។

នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចការងារនេះក្រុមហ៊ុនឯកភាពប្រាក់ឧបត្ថម្ភជូនកម្មករនិយោជិតតាមសេចក្តីណែនាំលេខ០២០/២៣ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន**១៥ដុល្លាអាមេរិក** ។

- តំណាងកម្មករនិយោជិតបានស្នើឲ្យក្រុមហ៊ុនរក្សាប្រាក់អត្ថប្រយោជន៍បន្ថែមដូចជាប្រាក់មុខងារ និងប្រាក់លើទឹកចិត្ត ABC ១០០% ក្នុងអំឡុងព្យួរកិច្ចសន្យាការងារ ។

- ក្រុមហ៊ុនឯកភាពផ្តល់ជូនប្រាក់អត្ថប្រយោជន៍បន្ថែមដូចជា៖

១.ប្រាក់មុខងារតួនាទី ផ្តល់ជូន១០០%

២.ប្រាក់លើទឹកចិត្ត ABC គិតជាសមមាត្រ ដោយយកប្រាក់លើទឹកចិត្ត ABC ប្រចាំខែតុលា មកធ្វើការគណនា ក្នុងអំឡុងព្យួរកិច្ចសន្យាការងារចាប់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ២០២៣។

៣.ក្រុមហ៊ុនរក្សាប្រាក់អត្ថប្រយោជន៍ផ្សេងៗដូចជាប្រាក់រង្វាន់ធ្វើការទៀងទាត់ចំនួន ១០ដុល្លា និងប្រាក់សាហ៊ុយធ្វើដំណើរនិងស្នាក់នៅចំនួន ៩ដុល្លា ។

- តំណាងកម្មករនិយោជិតឯកភាពទទួលយកតាមការផ្តល់ជូនរបស់ក្រុមហ៊ុននូវប្រាក់មុខងារតួនាទីនិងប្រាក់លើទឹកចិត្ត ABC ក្នុងអំឡុងព្យួរកិច្ចសន្យាការងារនេះ។

- ប្រាក់ឧបត្ថម្ភក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ ក្រុមហ៊ុនបើកជូននៅថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០២៣ ។

អង្គប្រជុំបានចប់វេលាម៉ោង ១៥និង៣០នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួល និង សហការគ្នាយ៉ាងរលូន។

ភ្នំពេញ.ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣

**ស្នាមមេដៃប្រតិភូបុគ្គលិក**

**នាយកក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ជេ.អេ.ដាប់បែលយូ ខ.អ J.A.W CO., LTD. KINGDOM OF CAMBODIA

SRI SUMARMI

ម៉េត សម្ផស្ស យ៉ោម លក្ខិនេ ភួង ណារីម សឿន សេង

ឌុច ឃាន់ ម៉ម តារិទ្ធ មឿង ឌី រឿង គីមស៊ី

ង៉ែត សុខរីម ទ្បោ វណ្ណី